Khmer Translation

Green River College ជឿជាក់ថាការចាក់វ៉ាក់សាំង ប្រឆាំងនឹង ជំងឺCOVID-១៩ គឺជាមធ្យោបាយល្អបំផុតដើម្បីការពារសុខភាព និងសុវត្ថិភាពនៃសហគមន៍ក្នុងបរិវេណសាលារបស់យើង។Green River College សូមណែនាំនិស្សិត និង បុគ្គលិកនៅមហាវិទ្យាល័យ ឱ្យទទួលចាក់វ៉ាក់សាំង ឱ្យបានឆាប់បំផុតដើម្បីការពារសុខភាព និងសុវត្ថិភាពទាំងអស់គ្នា។

គ្រប់និស្សិត ត្រូវតែបញ្ជាក់កាតវ៉ាក់សាំង ប្រឆាំងនឹង ជំងឺCOVID-១៩ រឺបញ្ជាក់ការលើកលែងពីលោកគ្រូពេទ្យ រឺ មន្ទីរសាសនា តាមអីនធឺណិត រៀងរាល់ត្រីមាស។ និស្សិតនៅត្រីមាសរដូវរងា (Winter Quarter) ត្រូវបញ្ជាក់តាមអីនធឺណិតកុំឱ្យហួសនឹងថ្ងៃច័ន្ទទី ២០ ខែធ្នូ។

**និស្សិតមានពីរជម្រើស ៖**

បញ្ជាក់កាតវ៉ាក់សាំង រឺការលើកលែងពីលោកគ្រូពេទ្យ រឺ មន្ទីរសាសនា

រឺ

ប្រកាសភាពរៀនតាមអីនធឺណិត

សេចក្តីប្រកាសភាពរៀនតាមអីនធឺណិត ទុកសម្រាប់តែនិស្សិតដែលមិនចង់ បញ្ជាក់កាតវ៉ាក់សាំង ប្រឆាំងនឹង ជំងឺCOVID-១៩ និងរៀនតាមអីនធឺណិតហើយប្រកាសថាមិនមានបំណងមកបរិវេណសាលា ថ្នាក់រៀន រឺមជ្ឈមណ្ឌលសេវាកម្ម។ និស្សិតត្រូវតែដាក់ស្នើសេចក្តីប្រកាសនេះ រៀងរាល់ត្រីមាស។

**បញ្ជាក់កាតវ៉ាក់សាំង រឺការលើកលែងពីលោកគ្រូពេទ្យ រឺ មន្ទីរសាសនា**

ការបញ្ជាក់ និងផ្ទៀងផ្ទាត់ដោយពីរជំហាន

1. បញ្ជាក់ រឺស្នើសុំការលើកលែង* នៅក្នុងគណនី ctcLink

    a. ចូលទៅកាន់គេហទំព័រដើមនៅ ctcLink Student Homepage > Immunization Attestation > COVID-19 Vaccination Attestation https://myaccount.ctclink.us/

    b. ហើយចូលទៅកាន់គេហទំព័រ How to add vaccination attestation or request an exemption in ctcLink - Green River College

2. បង្ហាញនិងផ្ទៀងផ្ទាត់កាតវ៉ាក់សាំងតាមអីនធឺណិត រឺ ជួបផ្ទាល់

    a. ចូលទៅកាន់គេហទំព័រ In Person and Zoom Lobby Stations for Student Vaccination Attestations and Verifications - Gator News - Green River College

    b. លេខ ctcLink

    c. អត្តសញ្ញាណរូបថតនិស្សិត

d. កាតវ៉ាក់សាំង រឺឯកសារជំនួស

e. ទូរស័ព្ទ រឺកុំព្យូទ័រដែលមានកាមេរ៉ា និងមីក្រូហ្វូន

*សម្រាប់ដែលស្នើសុំការលើកលែង នឹងទទួលបានអ៊ីមែលជាមួយនឹងជំហានបន្ទាប់

**ប្រកាសភាពរៀនតាមអ៊ីនធឺណិត**

https://www.surveymonkey.com/r/HLKB83V

សម្រាប់និស្សិតដែលរៀនតាមអ៊ីនធឺណិត និស្សិតក្រៅរដ្ឋ រឺនៅក្រៅសហរដ្ឋអាមេរិក៖ និស្សិតដែលមិនចង់បញ្ជាក់កាតវ៉ាក់សាំង ប្រឆាំងនឹង ជំងឺCOVID-១៩ និងរៀនតាមអ៊ីនធឺណិតតែប៉ុណ្ណោះ ហើយប្រកាសថាមិនមានបំណងមកបរិវេណសាលា ថ្នាក់រៀន រឺមជ្ឈមណ្ឌលសេវាកម្ម ត្រូវតែដាក់ស្នើសេចក្តីប្រកាសតាមគេហទំព័រខាងលើ រៀងរាល់ត្រីមាស។

និស្សិតដែលចង់ចុះឈ្មោះសម្រាប់ថ្នាក់ផ្ទាល់ រឺរៀនថ្នាក់កូនកាត់ រឺចង់ទទួលបានសេវាកម្មក្នុងបរិវេណសាលាសម្រាប់ត្រីមាសរដូវរងា រឺត្រីមាសនាពេលអនាគត ត្រូវតែបញ្ជាក់ និងផ្ទៀងផ្ទាត់ដោយពីរជំហាន។ GRC សូមណែនាំនិស្សិតទាំងអស់ដែលបានចាក់វ៉ាក់សាំង ប្រឆាំងនឹង ជំងឺCOVID-១៩ ឱ្យបំពេញជំហានទាំងនេះ មុនពេលមកថ្នាក់រៀនចាប់ពីថ្ងៃទី ៣ ខែមករា ឆ្នាំ ២០២២។

ការខកខានក្នុងការបំពេញតម្រូវការនេះនឹងបណ្តាលឱ្យមានការឈប់សម្រាកសិក្សា ផ្លាស់ប្តូរក្នុងទម្រង់ថ្នាក់ រឺការដកផ្នែករដ្ឋបាល។ ការបង្ហាញមិនពិត រឺក្លែងបន្លំ បំពានលើក្រមសីលធម៌របស់និស្សិត ហើយនឹងត្រូវទទួលការត្រួតពិនិត្យតាមផ្លូវតុលាការ។

Student Code of Conduct - Green River College